LONG BEACH UNIFIED • SCHOOL • DISTRICT

# កាលវិភាគកម្មវិធីជ្រើសរើសសាលាចូលវិទ្យាល័យ ឆ្នាំសិក្សា 2025-2026

## ត្រៀមរៀបចំ

**ថ្ងៃទី1 ខែតុលា រហូតដល់ *ថ្ងៃទី5 ខែធ្នូ ឆ្នាំ2025**

**សំរាប់ក្រុមគ្រួសារដែលមានកូនកំពុងរៀននៅសាលារបស់មន្ទីរអប់រំ LBUSD៖**

ឪពុកម្តាយ/អាណាព្យាបាលរបស់សិស្សដែលកំពុងរៀនថ្នាក់ទី8 នៅ LBUSD ត្រូវបាលលើកទឹកចិត្តឱ្យចូលប្រើប្រាស់ ភែរិនវ្យូ/ParentVUE ដើម្បីផ្ទៀងផ្ទាត់ថា ព័ត៌មានផ្ទាល់ខ្លួនទាំងអស់ រួមទាំងព័ត៌មានលំអិតអំពី អាសយដ្ឋាន និង បងប្អូនបង្កើត គឺឱ្យមានភាពត្រឹមត្រូវ។ ដើម្បីស្នើសុំធ្វើការផ្ទៀងផ្ទាត់និងកែសម្រួលព័ត៌មាននេះ  សូមទាក់ទងទៅ បុគ្គលិក ការិយាល័យ នៅតាមសាលារបស់កូនដែលកំពុងរៀនពេលបច្ចុប្បន្ន។

**សំរាប់សិស្សថ្មី ឬ សិស្សចាស់របស់មន្ទីរអប់រំ LBUSD ដែលត្រឡប់មករៀន វិញ៖**

គ្រួសាររបស់សិស្សថ្នាក់ទី8 ទាំងអស់ ដែលនៅពេលបច្ចុប្បន្នកំពុងរៀននៅសាលាឯកជន ឬ សាលាមិនមែនជារបស់រដ្ឋ ហើយរស់នៅក្នុងដែនកំណត់របស់សាលា LBUSD គួរតែបំពេញការចុះឈ្មោះចូលរៀនតាមរយៈការជ្រើសរើសសាលា **(the School of Choice)** ដែលដំណើរការតាមព័ន្ធអនឡាញ។ សូមត្រៀមរៀបចំដើម្បីដាក់បញ្ចូលរាល់ឯកសារ ដែលកំណត់ត្រូវមានទាំងឡាយ រួមមាន៖ ប្រតិបត្រពិន្ទុ និង ប័ណ្ណកំណត់ត្រាពិន្ទុសិស្ស។ ឯកសារជាក់ស្តែងក៏អាច ស្នើរឱ្យដាក់ជូនដល់សាលាផងដែរ។ សំរាប់ព័ត៌មានលម្អិត និង ជំនួយក្នុងការចុះឈ្មោះ សូមចូលមើល៖ LBUSD Enrollment Information។

**សំរាប់គ្រួសារដែលមិនរស់នៅក្នុងព្រំដែនកំណត់របស់ LBUSD៖** ការចុះឈ្មោះចូលរៀន នឹងត្រូវបានទទួលយក ក្នុងរដូវផ្ការីក ឆ្នាំ2026 ដោយអាស្រ័យទៅតាមកន្លែងដែលមាន។ សូមទាក់ទងសាលានៅក្នុងតំបន់រស់នៅរបស់អ្នក សំរាប់ការអនុញ្ញាតិផ្ទេរការសិក្សា ឆ្លងព្រំង់ដែនកំណត់ (IDP)។

## ស្វែងរក

**ថ្ងៃទី3 ខែវិច្ឆិកា រហូតដល់ ថ្ងៃទី10 ខែធ្នូ ឆ្នាំ2025**

**ស្វែងរកកម្មវិធីសិក្សាជំនាញអាជីពថ្នាក់វិទ្យាល័យ/Pathways និង កម្មវិធីផ្សេងៗទៀត៖**

ឪពុកម្តាយ/អាណាព្យាបាលត្រូវបានលើកទឹកចិត្តឱ្យចូលរួមព្រឹត្តការណ៍ដែលនឹងមានក្នុងពេលឆាប់ៗខាងមុខ  និងរចនា បង្កើតឡើង ដើម្បីលើកបង្ហាញអំពីសាលាដែលមានលក្ខណៈចម្រុះពូជសាសន៍ និង កម្មវិធីសិក្សាជំនាញអាជីពនានា ដែលមានបង្ហាត់នៅទូទាំងសាលាក្នុងមន្ទីរអប់រំ LBUSD។ យើងខ្ញុំជូនជាយោបល់ថា ចាប់ផ្តើមពីសាលាដែលស្ថិតក្នុង តំបន់រស់នៅរបស់អ្នក ហើយស្វែងរកមើលសាលា និងកម្មវិធីផ្សេងៗទៀត ដែលត្រូវគ្នានឹងចំណាប់អារម្មណ៍ និង គោលដៅរបស់សិស្សអ្នក។

- **8 វិច្ឆិកា៖ ពិព័រណ៍ស្តីពីការជ្រើសរើសសាលាវិទ្យាល័យ៖ ម៉ោង 9:00ព្រឹក-12:00ថ្ងៃត្រង់ នៅ វិទ្យាល័យ Cabrillo**
- **12 វិច្ឆិកា-10 ធ្នូ៖ ចុះទស្សនកិច្ចតាមសាលាវិទ្យាល័យ៖ ម៉ោង 5:00-8:00ល្ងាច**

សំរាប់បញ្ជីឈ្មោះព្រឹត្តការណ៍ទាំងស្រុង និងធនធានព័ត៌មានផ្សេងៗ ដើម្បីជួយដល់ដំណើរការសំរេចចិត្តរបស់អ្នក សូមចូលទស្សនា៖ 8th to 9th Grade Transition – LBUSD School Choice

## ដាក់ពាក្យ

**ថ្ងៃទី10 ខែវិច្ឆិកា រហូតដល់ ថ្ងៃទី12 ខែធ្នូ ឆ្នាំ2025**

**ការដាក់ពាក្យសុំរើសសាលាចូលរៀនវិទ្យាល័យ៖**

គ្រួសារសិស្សថ្នាក់ទី8 ទាំងអស់នឹងបំពេញការដាក់ពាក្យសុំរើសសាលាចូលរៀនវិទ្យាល័យ តាមប្រព័ន្ធអនឡាញ តាមរយៈ ភែរិនវ្យូ/ParentVUE។ សិស្សមានអាទិភាពទៅតាមលំនៅដ្ឋានរស់នៅក្នុងតំបន់សាលាវិទ្យាល័យរបស់ ពួកគេ តែទោះជាយ៉ាងណាក៏ដោយ ក៏អាចដាក់ពាក្យ សុំចូលរៀនក្នុងកម្មវិធីសិក្សាជំនាញអាជីព នៅតាមសាលា វិទ្យាល័យ LBUSD ផ្សេងទៀតបានផងដែរ។

# កាលវិភាគកម្មវិធីជ្រើសរើសសាលាចូលវិទ្យាល័យ

# ឆ្នាំសិក្សា 2025-2026

| | |
|---|---|
| | គ្រួសារទាំងឡាយគួរតែរាយបញ្ជីជម្រើសកម្មវិធីសិក្សាជំនាញអាជីពទៅតាមលំដាប់លំដោយលេខរៀងនៃចំណូលចិត្ត។ ដោយការជ្រើសរើសយកសាលា គឺអ្នកកំពុងតែប្តេជ្ញាចិត្តចំពោះការរៀបចំដាក់ឱ្យចូលកម្មវិធីសិក្សាជំនាញអាជីពនៅសាលានោះហើយ។។ ការរៀបដាក់ឈ្មោះសិស្ស ដែលកែប្រែ ក្រោយពីមានការចាត់តាំងសាលារួចហើយនោះ គឺនឹងត្រូវមានកំណត់។ |
| **កំណត់សាលា**<br><br>**ថ្ងៃទី15 ខែធ្នូ ឆ្នាំ2025**<br>**រហូតដល់**<br>**ថ្ងៃទី30 ខែមករា ឆ្នាំ2026** | **<u>ដំណើរការរៀបចំដាក់សិស្សទៅតាមសាលាទ្យាល័យ៖</u>**<br>សិស្សនឹងត្រូវគេដាក់ឱ្យលរៀនក្នុងកម្មវិធីសិក្សាជំនាញអាជីព ដោយផ្អែកតាមចំណូលចិត្តរបស់ពួកគេដែលមានលំដាប់លេខរៀងខ្ពស់បំផុត ស្របតាមតម្រូវការសិទ្ធិទទួលបាន  និងចំនួនកន្លែងដែលនៅមាន។ ឈ្មោះវិទ្យាល័យដែលបានកំណត់ឱ្យរៀន នឹងមានដាក់ជូនមើលនៅក្នុង **ParentVUE នៅថ្ងៃទី23 ខែមករា ឆ្នាំ2026 នៅម៉ោង 4:00ល្ងាច**<br><br>ក្នុងករណីដែលមានកំណត់មួយចំនួន គ្រួសារអាចស្នើដាក់ពាក្យប្តឹងតវ៉ាអំពីការចាត់តាំងសាលាដាក់ឱ្យសិស្សរៀននេះ។ សូមចូលមើលគេហទំព័រ និងស្រាវជ្រាវមើល នៅក្រោមកន្លែង «សំណួរដែលគេសួរញឹកញាប់»។<br><br>ការកំណត់ឈ្មោះសិស្សឱ្យចូលរៀនវិទ្យាល័យជាចុងក្រោយ គឺនឹងត្រូវគេបញ្ជាក់ នៅ**ថ្ងៃទី30 ខែមករា ឆ្នាំ 2026**។ |

**ប្រសិនបើលោកអ្នករស់នៅក្នុងតំបន់របស់ព្រំដែនកំណត់ មន្ទីរអប់រំ LBUSD ក៏ប៉ុន្តែមិនបានចុះឈ្មោះឱ្យទាន់ថ្ងៃទី5 ខែធ្នូ ឆ្នាំ2025 ទេនោះ គឺអ្នកនឹងត្រូវគេដាក់ឈ្មោះឱ្យរៀនក្នុងកម្មវិធីសិក្សាជំនាញអាជីព អាស្រ័យទៅតាមកន្លែងដែលមាន។*

**សំរាប់ព័ត៌មានថ្មីៗបំផុត សូមពិនិត្យមើលគេហទំព័ររបស់យើង៖ www.lbschools.net**

**ការិយាល័យសមធម៌ ការចូលរួម និងភាពជាដៃគូរ (EEP) របស់មន្ទីរអប់រំ LBUSD**